# ខ្លឹមសារសង្ខេប

# ដីការបស់អង្គជំនុំជម្រះតុលាការកំពូល (តុលាការកំពូល) នៃ អវតក ស្ដីពី ការអនុវត្តតាមជាបន្ទាន់ តាមវិធាន ១០៨ នៃវិធានផ្ទៃក្នុង

**<u>ពាក្យគន្លឹះ៖ និយមន័យសំណុំរឿង, ការបកស្រាយមាត្រា, ប្រភេទបណ្ដឹងសាទុក្ខ</u>**

១. តុលាការកំពូល មានសមត្ថកិច្ច ពិនិត្យបណ្ដឹងសាទុក្ខ (ធម្មតា) ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង (សាលាដំបូង) ឬបណ្ដឹងបន្ទាន់បង្គំ (Immediate Appeal) ដូចជាបណ្ដឹងស្នើសុំរបស់ជនជាប់ចោទឲ្យនៅក្រៅឃុំក្នុងអំឡុងពេលសវនាការជាដើម។ ជាការអនុវត្តកន្លងមក ក្រឡាបញ្ជីនៃសាលាដំបូង ផ្ដល់នូវតែផ្នែកខ្លះ នៃសំណុំរឿង (Case File) ជាមួយនឹងបណ្ដឹងពាក់ព័ន្ធ។ ក្រឡាបញ្ជី នៃសាលាដំបូង ពិនិត្យមើល វិធាន ១០៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងប្រព័ន្ធតុលាការកម្ពុជា (អវតក) ហើយអះអាងថា សំណុំរឿង ក្នុងបរិបទនៃបណ្ដឹងបន្ទាន់បង្គំ មិនទាំងមូល ដែលត្រូវបញ្ជូនទៅតុលាការកំពូល ដូចក្នុងករណីនៃបណ្ដឹងសាទុក្ខធម្មតាទេ (កថាខ័ណ្ឌទី២ និង ៣)។

២. តុលាការកំពូល យោងដល់ សន្ទានុក្រម នៃវិធានផ្ទៃក្នុង ដែលកំណត់ថា៖ សំណុំរឿង “*សំដៅដល់គ្រប់ឯកសារទាំងអស់ ...រាប់បញ្ចូលនូវសេចក្ដីសម្រេចនិងឯកសារភ្ជាប់ ...នៅគ្រប់ដំណាក់កាលនៃនីតិវិធី រួមទាំងកំណត់ត្រាដំណើរការក្ដីនៅមុខអង្គជំនុំជម្រះសាលាដំបូងផងដែរ*”។ ការបកស្រាយរបស់ក្រឡាបញ្ជីនៃសាលដំបូង គ្មានមូលដ្ឋានក្នុងច្បាប់ទេ។ តុលាការកំពូលត្រូវការឯកសារទាំងអស់ សម្រាប់សម្រេចលើបណ្ដឹងដោយសមស្រប ហើយឯកសារប្រភេទណា ជាការសម្រេចដោយឆន្ទានុសិទ្ធិរបស់តុលាការកំពូល។ តុលាការកំពូលត្រូវចូលមើលសំណុំរឿងទាំងមូលដោយគ្មានកម្រិត។ ផ្អែកតាមមូលដ្ឋានទាំងនេះ តុលាការកំពូលសម្រេច៖ *បញ្ជាឲ្យសាលាដំបូងបញ្ជូនឯកសារសំណុំរឿងទាំងស្រុង មកតុលាការកំពូល អនុលោមតាមវិធាន ១០៨*។

**<u>កំណត់សំគាល់</u>**៖ ១. តុលាការកំពូល មានអំណាច *Ex Officio* ចេញដីកាបញ្ជាដោយឯកឯងបាន។ ២. ដីកានេះ ជាប្រយោជន៍សម្រាប់ពិចារណាដោយតុលាការកម្ពុជា នៅពេលប្រឈមនឹងបញ្ហាផ្លូវច្បាប់ស្រដៀងគ្នា ជាពិសេសពាក់ព័ន្ធនឹងនិយមន័យនៃពាក្យ “សំណុំរឿង”។

Supreme Court Chamber, Case 002, Order for Immediate Compliance with Rule 108 of the Internal Rules, E238/9/1/4, 12 March 2013 (Public)